**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.០០០ហិកតា ក្នុងតំបន់ការពារទេសភាព បន្ទាយឆ្មារ ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១ៈ-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ៦.០០០(**ប្រាំមួយពាន់**) ហិកតា ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចិរភាពនៃតំបន់ការពារទេសភាពបន្ទាយឆ្មារ ភូមិសាស្ត្រស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៩៧ សជណ.កស ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២ៈ-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣ៈ-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០១១

ទីស្តីការគណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

## ផែនទី ទីតាំងដី វិនិយោគ និងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ជាតិអភិវឌ្ឍន៍ ...

### ស្ថិតនៅក្នុង តំបន់ការពារទេសភាពបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ លើផ្ទៃដី ៦០០០ ហ.ត




សញ្ញាសំគាល់
ផ្លូវជាតិ
ផ្លូវលំ
ស្ទឹង . អូរ
ទីតាំងវិនិយោគ

| Id | N | Coor_x | Coor_y |
|---|---|---|---|
| 1 | A | 285127 | 1563938 |
| 2 | B | 283344 | 1562889 |
| 3 | C | 282681 | 1563896 |
| 4 | D | 281814 | 1566503 |
| 5 | E | 281540 | 1568618 |
| 6 | F | 286400 | 1570886 |
| 7 | G | 285908 | 1572004 |
| 8 | H | 289089 | 1573557 |
| 9 | I | 289578 | 1572466 |
| 10 | J | 289862 | 1572125 |
| 11 | K | 289188 | 1571214 |
| 12 | L | 292581 | 1566314 |
| 13 | M | 287037 | 1562765 |
| 14 | N | 284156 | 1567718 |
| 15 | O | 282999 | 1568461 |
| 16 | P | 282707 | 1568193 |
| 17 | Q | 282926 | 1567042 |
| 18 | R | 282451 | 1566753 |
| 19 | S | 283684 | 1565233 |
| 20 | T | 284128 | 1565427 |

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ... ឆ្នាំ ២០១១

ហត្ថលេខា

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ... ឆ្នាំ ២០១១